សម្ព័ន្ធអង្គការសង្គមស៊ីវិលប្រឆាំងអំពើពុករលួយ
Coalition of Civil Society Organizations Against Corruption

# សេចក្តីប្រកាសព័ត៌មាន

## គណបក្សនយោបាយចំនួន ១០ សន្យាថា
## នឹងអនុម័តច្បាប់ប្រឆាំងអំពើពុករលួយដែលមានស្តង់ដារអន្តរជាតិ បើសិនជាខ្លួនជាប់ឆ្នោត

*ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៨*

គណបក្សនយោបាយចំនួន ១០ ក្នុងចំណោមគណបក្សនយោបាយចំនួន ១១ ដែលបានចុះបញ្ជីដើម្បីប្រកួតប្រជែងនៅក្នុងការបោះឆ្នោត នៅថ្ងៃ ២៧ ខែកក្កដា ឆ្នាំ ២០០៨ បានប្រកាសថា ខ្លួននឹងអនុម័តច្បាប់ប្រឆាំងអំពើពុករលួយដែលខ្មែរគ្រប់រូបទន្ទឹងរង់ចាំជាយូរមកហើយនោះ យ៉ាងយូរបំផុតក្នុងរយៈពេល៦ខែ បន្ទាប់ពីការបង្កើតរដ្ឋាភិបាលអាណត្តិថ្មី ប្រសិនបើខ្លួនជាប់ឆ្នោត។ គណបក្សទាំងនោះបាននិយាយថា ច្បាប់ប្រឆាំងអំពើពុករលួយនោះគប្បីមានស្តង់ដារអន្តរជាតិ។

គណបក្សនយោបាយទាំងនោះ បានសំដែងការតាំងចិត្តរបស់ខ្លួនស្តីពីការប្រឆាំងអំពើពុករលួយ នៅក្នុងការឆ្លើយតបរបស់ខ្លួន ទៅនឹងលិខិតដែលបានដាក់ជូនកាលដើមខែមិថុនាកន្លងទៅនេះ ដោយសម្ព័ន្ធអង្គការសង្គមស៊ីវិលប្រឆាំងអំពើពុករលួយ ដែលជាក្រុមមួយរួមមានអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិជិត ៥០ អង្គការ។

គណបក្សមួយ ក្នុងចំណោមគណបក្សនយោបាយទាំង ១១ គឺគណបក្សប្រជាជនកម្ពុជា មិនបានឆ្លើយតបទៅនឹងលិខិតរបស់សម្ព័ន្ធអង្គការសង្គមស៊ីវិលប្រឆាំងអំពើពុករលួយទេ។ សម្ព័ន្ធអង្គការសង្គមស៊ីវិលកម្ពុជាប្រឆាំងអំពើពុករលួយ បានផ្ញើលិខិតនេះជូនប្រធានគណបក្សនយោបាយទាំងនោះដោយផ្ទាល់តែម្តង ហើយចំពោះគណបក្សប្រជាជនកម្ពុជា គឺជូនទៅសម្តេច **ជា ស៊ីម** ដោយចម្លងជូនមួយច្បាប់ទៅទីស្នាក់ការកណ្តាលរបស់គណបក្ស។ ក៏ប៉ុន្តែ សម្ព័ន្ធអង្គការសង្គមស៊ីវិលកម្ពុជា ប្រឆាំងអំពើពុករលួយ មិនបានទទួលការឆ្លើយតបណាមួយឡើយ រហូតដល់ថ្ងៃ ២៣ មិថុនា ឆ្នាំ ២០០៨ ដែល ជាថ្ងៃកំណត់ចុងក្រោយ។

លិខិតដែលសម្ព័ន្ធអង្គការសង្គមស៊ីវិលប្រឆាំងអំពើពុករលួយ បានផ្ញើទៅកាន់គណបក្សនយោបាយទាំងនោះ ចោទជាសំណួរថា៖ បើសិនជាជាប់ឆ្នោតបានឡើងដឹកនាំប្រទេស តើគណបក្សយល់ព្រមអនុម័តច្បាប់ប្រឆាំងអំពើពុករលួយឬទេ ក្នុងរយៈពេល ៦ ខែយ៉ាងយូរ បន្ទាប់ពីបង្កើតរដ្ឋាភិបាលអាណត្តិថ្មី និងថាតើច្បាប់នោះមានស្តង់ដារអន្តរជាតិឬទេ ? នៅលើលិខិតឆ្លើយតប គណបក្សនយោបាយខ្លះបានសរសេរអធិប្បាយបន្ថែមពីការតាំងចិត្តរបស់ខ្លួន ហើយគណបក្ស នយោបាយទាំង ១០សុទ្ធតែបានសន្យាចាត់វិធានការទាំងពីរនេះ។

សូមបញ្ជាក់ថា គណបក្សនយោបាយចំនួន ៤ គឺ គណបក្ស សម រង្ស៊ី គណបក្សសិទ្ធិមនុស្ស គណបក្សនរោត្តម រណឫទ្ធិ និងគណបក្សហ្វ៊ុនស៊ិនប៉ិច ក៏បានចុះហត្ថលេខា និងគាំទ្រផងដែរដល់សន្និសញ្ញានិម្មិតរូបបាតដៃស្អាតស្អំ ដែលផ្តួចផ្តើមឡើងដោយសម្ព័ន្ធអង្គការសង្គមស៊ីវិលប្រឆាំងអំពើពុករលួយ នៅក្នុងយុទ្ធនាការប្រមូលស្នាមមេដៃ និងហត្ថលេខាប្រជាពលរដ្ឋ ដើម្បីទាមទារឱ្យមានការអនុម័តច្បាប់ប្រឆាំងអំពើពុករលួយ ។

សម្ព័ន្ធអង្គការសង្គមស៊ីវិលប្រឆាំងអំពើពុករលួយ បានធ្វើយុទ្ធនាការទូទាំងប្រទេសក្នុងរយៈពេល ៥ ខែ ដើម្បីធ្វើការអប់រំបង្កើនការយល់ដឹង ពីការខាតបង់ និងផលវិបាកនៃអំពើពុករលួយមកលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ហើយទន្ទឹមនឹងនោះដែរដើម្បីប្រមូលការគាំទ្រដល់ការចាត់វិធានការយ៉ាងមាំទាំប្រឆាំងអំពើពុករលួយ ជាពិសេសគឺការអនុម័តច្បាប់ប្រឆាំងអំពើពុករលួយដែលមានស្តង់ដារអន្តរជាតិ ឱ្យបានឆាប់រហ័ស ។

យុទ្ធនាការដែលធ្វើឡើងដោយសម្ព័ន្ធអង្គការសង្គមស៊ីវិលប្រឆាំងអំពើពុករលួយ មានគំរោងប្រមូលស្នាមមេដៃ ឬហត្ថលេខា ឱ្យបាន ១លាន នៅត្រឹមដំណាច់ខែមេសា (ពោលគឺមានន័យថា ប្រមូលស្នាមមេដៃ ឬហត្ថលេខាចំនួន ៧00 000 បន្ថែមទៅលើស្នាមមេដៃ ឬហត្ថលេខាចំនួន ៣00 000 ដែលប្រមូលបានកាលពីឆ្នាំកន្លងផុតទៅ)។ តែទោះជាយ៉ាងណាក៏ដោយ មកទល់ពេលនេះប្រជាពលរដ្ឋនៅតែបន្តចុះហត្ថលេខា ឬផ្តិតមេដៃលើសន្និសញ្ញាប្រឆាំងអំពើពុករលួយ ហើយឥឡូវនេះ ចំនួនស្នាមមេដៃ ឬហត្ថលេខាដែលប្រមូលបាន គឺលើសពី ១ លាន ១ សែនទៅទៀត។ យុទ្ធនាការដ៏ធំស្វែងរកការគាំទ្រញត្តិបែបនេះ គឺជាកិច្ចខិតខំប្រឹងប្រែងប្រកបដោយជោគជ័យមួយធំបំផុតនៅ ក្នុងប្រទេសកម្ពុជា។

ញត្តិប្រឆាំងអំពើពុករលួយ ត្រូវបានប្រគល់ជូនរដ្ឋសភា កាលពីថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០៨ កន្លងទៅនេះ តាមរយៈគណៈកម្មការទី ១ របស់រដ្ឋសភា។ សម្ព័ន្ធអង្គការសង្គមស៊ីវិលកម្ពុជាប្រឆាំងអំពើពុករលួយ ក៏បានផ្ញើលិខិតទៅកាន់រាជរដ្ឋាភិបាលកម្ពុជាផងដែរ ដើម្បីសុំប្រគល់ជូនញត្តិទាំងនោះ ហើយកំពុងតែរង់ចាំការឆ្លើយតប ។

សំរាប់ព័ត៌មានបន្ថែមទាក់ទងទៅនឹងយុទ្ធនាការបាតដៃស្អាតស្អំ និងលិខិតទៅកាន់គណបក្សនយោបាយ សូមទាក់ទង :


| | |
|---|---|
| លោក យ៉ង គឹមអេង | ទូរស័ព្ទ : 016 828211 |
| លោក ប៉ុក ពុទ្ធារិទ្ធិ | ទូរស័ព្ទ : 012 668 522 |
| លោក សន ជ័យ | ទូរស័ព្ទ : 012 445 642 |
| លោកស្រី ម៉ម ស៊ីថា | ទូរស័ព្ទ : 011 722 028 |
| លោកស្រី ហួតរតនៈ | ទូរស័ព្ទ : 012 802 551 |